កោះសន្តិភាព ឆ្នាំទី៤២ លេខ៦៦៩២ ថ្ងៃសុក្រ ទី០៣ ខែកក្កដា ឆ្នាំ២០០៩




បុរសរូបនេះបីឪពុកមានជម្ងឺចេញពីផ្ទះដែលគ្រឿងចក្រកំទេចដោយអំណាចសាលក្រម (ចោមចៅ)

# ក្រុមហ៊ុនឈ្មុះក្តីអនុវត្តសាលក្រមរុះរើលំនៅឋានអ្នកក្រីក្ររាបដល់ដី

ខេត្តកណ្តាល : កំលាំងសមត្ថកិច្ចចំរុះរបស់ខេត្តកណ្តាល១ក្រុមធំ រួមមានមន្ត្រីតុលាការ មន្ត្រីសាលាខេត្ត កំលាំងប្រដាប់អាវុធ មានប៉ូលិស ប៉េអឹមខេត្ត មន្ត្រីសាលាស្រុកអង្គស្នួល កំលាំងប៉ូលិស ប៉េអឹមស្រុក អង្គស្នួល បានចុះអនុវត្តសាលក្រមលើដីទំនាស់មួយកន្លែងដែលតាមការអះអាងថា បានអូសបន្លាយពេលជាង១០ឆ្នាំ មកហើយ ។ សកម្មភាពអនុវត្តសាលក្រមនោះធ្វើឡើងយ៉ាងសាហាវកាលពីវេលាព្រឹកថ្ងៃទី២ ឧសភា ឆ្នាំ២០០៩ នៅលើ ដីទំនាស់ខាងលើដែលមានទីតាំងស្ថិតនៅភូមិត្រពាំងក្រសាំង ឃុំបែកចាន ស្រុកអង្គស្នួល ។ ការអនុវត្ត សាលក្រមនេះប្រជាពលរដ្ឋ៥នាក់ ត្រូវចាប់រ៉ៃខ្នោះដាក់រថយន្ត ព្រោះហ៊ានទទឹងមុខសឹក និងលំនៅឋាន ព្រមទាំងផ្ទះជួល ឱ្យកម្មករប្រមាណជាង៣០ខ្នង ភាគច្រើនជាប្រភេទផ្ទះសង់ពីថ្មប្រក់ដំបូលស័ង្កសី ត្រូវវាយនឹងឈូសកំទេចចោល ទាំងស្រុងដោយគ្រឿងចក្រ ។ ជាបន្ទាន់ភ្លាមៗ ក្រុមហ៊ុនដែលធ្វើសង្គ្រាម ឈ្នះក្តី តាមរយៈតុលាការ

នោះបានធ្វើរបងស័ង្កសីបិទបាំងដីនោះភ្លាមៗ យ៉ាងតក់ក្រហល់បំផុត ។ ក្រៅពីនេះ មានកម្មករ កម្មការិនី រាប់រយនាក់ ក៏ត្រូវទឹកភ្នែក ដោយសារបាត់បង់របស់របរសម្ភារៈប្រើប្រាស់ខ្ទេចខ្ទី ព្រោះទុកនៅក្នុងបន្ទប់ផ្ទះជួលដែលត្រូវវាយកំទេចចោល ដោយសារតែពួកគេរវល់តែធ្វើការនៅរោងចក្រដោយមិនដឹងខ្លួន ។ ជាការកត់សំគាល់សំរាប់កម្មកររោងចក្រក្រោយពេលដឹងថា ផ្ទះជួលរបស់ខ្លួនត្រូវបានកំទេចចោលរាបដល់ដីនោះ ក៏រត់ចេញពីរោងចក្រទៅមើលមិនឃើញរបស់របរ ក៏បានស្រែកទ្រហោយំកងរំពង ។ ក្នុងហេតុការណ៏នោះដែរ អ្នកយកព័ត៌មានកាសែតរស្មីកម្ពុជាម្នាក់ត្រូវបានតំណាងក្រុមហ៊ុន ដែលជាអ្នកឈ្នះក្តីដណ្តើមយកម៉ាស៊ីនថតរូប ព្រោះហ៊ានថតរូបពីសកម្មភាពវាយបំផ្លាញផ្ទះប្រជាពលរដ្ឋ និងថតរូបប្រជាពលរដ្ឋដ៏កំសត់ម្នាក់ ដែលបីឪពុកចាស់ និងមានជំងឺរត់ចេញពីផ្ទះទាំងព្រលឹងចុងសក់គេចឱ្យផុតពីការវាយកំទេចចោលនោះ ចំណែកកោះសន្តិភាពបានគេចចេញទាន់ពីជនឃោរឃៅនេះ ។ ទាក់ទិនទៅនឹងសកម្មភាពដ៏កាចសាហាវនេះ ក្រុមហ៊ុនដែលជាអ្នកឈ្នះក្តីពុំបានផ្តល់ព័ត៌មាន ឬបំភ្លឺប្រាប់អ្នកកាសែតទេ ហើយការវាយកំទេចលំនៅឋានប្រជាពលរដ្ឋចោលបែបនេះ មិនដឹងថា យោងតាមឯកសារអ្វីខ្លះ ឬបានជូនដំណឹងឱ្យដឹងមុន ឬអត់នោះឡើយ ។ ប៉ុន្តែការអនុវត្តន៏សាលក្រមនោះ ពិតជាបានធ្វើឡើងក្រោមតំណក់ ទឹកភ្នែកអ្នករងគ្រោះរាប់រយនាក់ដែលបានស្រែកដាក់បណ្តាសាគួរឱ្យព្រឺក្បាល




។

ដោយឡែកប្រជាពលរដ្ឋដែលត្រូវបានកំទេចលំនៅឋានអស់ហើយនោះ បានឱ្យដឹងថា ដីដែលត្រូវអនុវត្តសាលក្រម នាពេលនេះមានទំហំ៣៥ហិកតា ដែលប្រជាពលរដ្ឋចំនួន១១៧គ្រួសាររស់នៅ គឺជាប្រភេទដី ស្រែចំការ និងលំនៅឋាន របស់ពួកគាត់ ដែលបានកាន់កាប់បង្កបង្កើនផល និងរស់នៅតាំងពីឆ្នាំ១៩៧៩មកម្ល៉េះ។ លុះដល់ថ្ងៃទី៩ កញ្ញា ឆ្នាំ១៩៩៥ មានឈ្មោះយិន សាយ ភេទស្រី អាយុ៤២ឆ្នាំ មានទីលំនៅ ភូមិប្រទះឡាង សង្កាត់ប្រទះឡាង ខណ្ឌដង្កោ ដែលបច្ចុប្បន្ន មិនដឹងស្នាក់នៅទីណាពិតប្រាកដនោះទេ ។ តាមប្រភពដដែលបានបន្តទៀតថា ឈ្មោះយិន សាយ នោះ បានបង្កើតគណៈកម្មការទិញដីដែលគាត់ធ្វើជាប្រធានបានចុះទិញដីពីប្រជាពលរដ្ឋឃុំបែកចានទំហំ៧៥ហិកតា ដែលដីនោះស្ថិតនៅក្នុងភូមិចំនួន៣ គឺភូមិត្រពាំងប្រុយ ភូមិបែកចាន និងភូមិត្រពាំងក្រសាំងទៅឱ្យក្រុមហ៊ុន ។ ពេលនោះដែរប្រជាពលរដ្ឋ ដែលជាម្ចាស់កម្មសិទ្ធិដីទំហំ៤០ហិកតា ស្ថិតក្នុងភូមិត្រពាំងប្រុយ និងភូមិបែកចាន ទទួលបានលុយកក់ដី គ្រប់ចំនួនទាំងអស់ ។ ប្រភពដដែលបានបន្តទៀតថា ដោយឡែកប្រជាពលរដ្ឋចំនួន១១៧គ្រួសារ នៅក្នុងភូមិត្រពាំងក្រសាំង ដែលជាម្ចាស់កម្មសិទ្ធិដីទំហំ៣៥ហិកតា ទទួលបានប្រាក់កក់ត្រឹមតែ៥ភាគរយប៉ុណ្ណោះ ពីក្រុមអ្នកគួកជេរ គឺនៅថ្ងៃទី១៣ តុលា ឆ្នាំ១៩៩៥ ពុំបានទទួលដោយផ្ទាល់ពីក្រុមហ៊ុនដែលជាអ្នកទិញនោះឡើយ។ លុះដល់ថ្ងៃទី២៩ វិច្ឆិកា ឆ្នាំ១៩៩៥ ពួកគាត់បានឯកភាពគ្នាទទួលប្រាក់ម្តងទៀត ដោយធ្វើកិច្ចសន្យាកក់បីដំណាក់កាល គឺដំណាក់កាលទី ១-ក្រុមហ៊ុនកក់ប្រាក់១០ភាគរយ នៅថ្ងៃទី១០ ធ្នូ ឆ្នាំ១៩៩៥ ។ ដំណាក់កាលទី២-ត្រូវកក់៣៥ភាគរយ គឺនៅថ្ងៃទី៣០ មករា ឆ្នាំ១៩៩៦ និងដំណាក់កាលទី៣ ត្រូវកក់ចំនួន៥០ភាគរយនៃប្រាក់កក់បង្គ្រប់ គឺនៅថ្ងៃទី៣០ មិថុនា ឆ្នាំ១៩៩៦ ។ ពួកគេនិយាយទៀតថា ប៉ុន្តែក្រុមហ៊ុននោះក្រឡិចក្រឡុចមិនគោរពកិច្ចសន្យានោះទេ ដល់ពេលកំណត់ មិនប្រគល់លុយឱ្យប្រជាពលរដ្ឋឡើយរហូតដីនោះត្រូវដាច់ បើគិតតាមច្បាប់កិច្ចសន្យាប្រាក់កក់ត្រូវកាត់ដីនៅជាកម្មសិទ្ធិ របស់ពួកគាត់ដដែល។ បន្ទាប់ពីមានរឿងហេតុបោកប្រាស់បែបនេះ ពួកគាត់បានដាក់ពាក្យប្តឹងទៅតុលាការខេត្តកណ្តាល ដើម្បីទាមទារសុំយកបង្កាន់ដៃដីមកវិញ ប៉ុន្តែឈ្មោះយិន សាយ មិនព្រមឱ្យ និងបានប្តឹងតបតពួកគាត់វិញ ធ្វើឱ្យកើតមានការក្តីក្តាំគ្នាអូសបន្លាយអស់រយៈពេល១០ឆ្នាំ ។



គ្រឿងចក្រត្រូវបានគេបញ្ជាឱ្យកាយកំទេចលំនៅឋានជួលរាបដល់ដី (រូបថត ចោមចៅ)

ប្រជាពលរដ្ឋបាននិយាយថា ពេលនេះដីពុំដឹងថាដីនេះត្រូវធ្លាក់ទៅលើក្រុមហ៊ុនណាក្រោយគេនោះឡើយ ។ ប៉ុន្តែស្រាប់តែមានការអនុវត្តសាលក្រម វាយកំទេចផ្ទះសំបែងរបស់ពួកគាត់ខ្ទេចខ្ទីអស់ គ្មានសល់អ្វីឡើយ ដើម្បីយកដី ។ ប្រការគួរឱ្យកត់សំគាល់នោះ គឺការអនុវត្តសាលក្រមរបៀបអ្នកភូមិមិនបានដឹងមុន គឺលើកទ័ពទៅបោសសំអាតកំទេចចោលទាំងកំហឹងតែម្តង ។ ឯអ្នកដែលរងគ្រោះធ្ងន់ ដោយការបាត់បង់ទ្រព្យសម្បត្តិអស់នោះគឺក្រុមកម្មកររោងចក្រដែលជួលផ្ទះគេ នៅពេលនេះសល់តែមួយចង្កេះដូចភ្លើងឆេះផ្ទះ។ ចំណែកមនុស្សចាស់ជរា ខ្លះបានកូនចៅរត់ទៅបីត្រកងចេញពីផ្ទះឱ្យផុតពីប្រមោយគ្រឿងចក្រ ដែលកំពុងបើកបរកិនឈូសកំទេច។ អ្នកដែលឃើញហេតុការណ៍អនុវត្តសាលក្រមរបស់អ្នកឈ្នះក្តីនេះ ពិតជាកាចសាហាវមែន ។ កោះសន្តិភាពបានព្យាយាមសុំការបំភ្លឺពីអាជ្ញាធរ និងតំណាងក្រុមហ៊ុនឈ្នះក្តីដែរ តែពុំមានការបំភ្លឺណាមួយឡើយ មានតែការគំរាមដកហូតម៉ាស៊ីនថតតែប៉ុណ្ណោះ នឹងចាត់ទុកអ្នកកាសែត ជាសត្រូវផងដែរ ។